ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# លិខិតជូនពរ

**សូមគោរពជូន**
**លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា- ព្រឹទ្ធសភា និងអធិការកិច្ច**
**ក្នុងឱកាសចម្រើនជន្មាយុគម្រប់ ៦៩ឆ្នាំ ឈានចូល ៧០ឆ្នាំ**

**លោកជំទាវកិត្តិសង្គហបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់**

ក្នុងឱកាសចម្រើនជន្មាយុគម្រប់ ៦៩ឆ្នាំ ឈានចូល ៧០ឆ្នាំ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២២ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមជួយប្រោះព្រំសព្ទសាធុការពរ សិរីសួស្តី ជ័យមង្គល វិបុលសុខ បវរមហាប្រសើរជូន **លោកជំទាវកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច** សូមមានសុខភាពល្អបរិបូរណ៍ បញ្ញាញាណវាងវៃ និងជ័យជម្នះគ្រប់ប្រការ ដើម្បីបន្តចូលរួមចំណែកដឹកនាំកិច្ចការរាជរដ្ឋាភិបាលឱ្យកាន់តែរីកចម្រើនជាលំដាប់បន្ថែមទៀត។

ក្នុងឱកាសដ៏ថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវការកោតសរសើរ **លោកជំទាវកិត្តិសង្គហបណ្ឌិត** ដោយស្មោះអស់ពីដួងចិត្ត ចំពោះស្នាដៃការងារបម្រើជាតិមាតុភូមិ ក៏ដូចជាភាពជាគំរូដល់ស្ត្រីខ្មែរទូទៅតាមរយៈតួនាទីនិងភារកិច្ចដ៏ឧត្តុង្គឧត្តមក្នុងបេសកកម្មដឹកនាំក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រួមចំណែកជាមួយប្រមុខរាជរដ្ឋាភិបាលកម្ពុជាក្នុងការងារលើកកម្ពស់នីតិរដ្ឋនៅកម្ពុជា ដើម្បីឧត្តមប្រយោជន៍ជាតិនិងប្រជាជន។ **លោកជំទាវកិត្តិសង្គហបណ្ឌិត** ពិតជាស្ត្រីខ្មែរដ៏ឆ្នើមមួយរូបដែលបានរួមចំណែកក្នុងពលិកម្មគ្រប់បែបយ៉ាង ដើម្បីសុខសន្តិភាពនិងការរីកចម្រើនរបស់សង្គមជាតិនាពេលកន្លងមករហូតដល់ពេលបច្ចុប្បន្ន ហើយក៏ជាគំរូដ៏ឧត្តមសម្រាប់ស្ត្រីខ្មែរទូទៅ តាមរយៈការចូលរួមក្នុងគ្រប់សកម្មភាពដើម្បីលើកកម្ពស់តម្លៃសីលធម៌សង្គមខ្មែរ និងការរក្សាការពារ លើកស្ទួយតម្លៃនិងសិទ្ធិស្ត្រីខ្មែរទូទៅ។

យើងខ្ញុំទាំងអស់គ្នាសូមគោរពជូនពរ **លោកជំទាវកិត្តិសង្គហបណ្ឌិត ព្រមទាំងក្រុមគ្រួសារ** សូមមានសុខភាពល្អបរិបូរណ៍ និងសមប្រកបនឹងពុទ្ធពរដ៏មហាប្រសើរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោកជំទាវកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវគោរវកិច្ចដ៏ខ្ពង់ខ្ពស់ ពីយើងខ្ញុំ៕

ថ្ងៃ ព្រហស្បតិ៍ ១៤កើត ខែ ស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែសីហា ឆ្នាំ២០២២
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
រដ្ឋមន្ត្រី

ព្រុំ-សុខា